# ការពង្រឹងភាពជាអ្នកដឹកនាំដល់ប្រជាពលរដ្ឋ

ធាតុពិតនៃសង្គមបច្ចុប្បន្ន បានឆ្លុះបញ្ចាំងឱ្យឃើញថាមានការកើនឡើងនូវវិសមភាព ដូចជាការរើសអើង និង ទំនាស់ ។ បញ្ហានៃភាពក្រីក្រ និង គម្លាតគ្នា បានបង្កឱ្យកើតមានបញ្ហាទំនាស់ផ្សេងៗ និង បញ្ហាសន្តិសុខ ។ រហូតមកដល់ពេលនេះសំឡេងនៃក្រុមជនដែលត្រូវបានគេ ផាត់ចេញបានចាប់ផ្តើមមានការយកចិត្តទុកដាក់ឱ្យឃើញច្បាស់ថា យើងខ្វះយន្តការ ដើម្បីនាំពួកគេឱ្យចូលរួមក្នុងកិច្ចសន្ទនាស្ថាបនា និង ផ្លាស់ប្តូរសង្គម ។ ប្រជាពលរដ្ឋ ដែលមានទស្សនវិស័យក្នុងភាពជាអ្នកដឹកនាំនៅមូលដ្ឋាន អាចដើរតួនាទីស្ថាបនា ប្រកបដោយ សារៈសំខាន់ នៅក្នុងបរិបទនេះ ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននៃពិភពលោក ការលើកស្ទួយឱ្យមានមនសិការសមូហភាព និង ការកសាងកម្លាំង ក្នុងចំណោមស្ត្រី ក្រុមជនរស់នៅតាមជ្រលងភ្នំ (dalits) និង ក្រុមកុលសម្ព័ន្ធ (ដូចគ្នានឹងក្រុមជនដែលត្រូវបានផាត់ឆ្ងាយពីសង្គម) រយៈពេលបីទសវត្សចុងក្រោយកន្លងមកនេះ បានបង្ហាញលទ្ធផលថាមានការជំរុញការផ្លាស់ប្តូរថ្មី នៅក្នុងក្រុមមនុស្ស និងសមាគម នៃសហគមន៍មូលដ្ឋាន (Community–Based Organiation)។ ការប្រមូលផ្តុំជាក្រុមសហគមន៍ និង សមាគមជាច្រើនទាំងនេះ បានចេញមកពីលទ្ធផល នៃកម្មវិធីអភិវឌ្ឍន៍ ដូចជាក្រុមជួយខ្លួនឯង (Self-Help-Groups ) ឬ គណៈកម្មាធិការអ្នកប្រើប្រាស់តាមផ្នែកផ្សេងៗ (ឧទាហរណ៍ : គណៈកម្មាធិការការពារព្រៃឈើ សមាគមអ្នកប្រើប្រាស់ទឹក គណៈកម្មាធិការ ទីជម្រាល... ។ល ។)។ សមាគមដែលមានមូលដ្ឋាននៅសហគមន៍ជាច្រើនត្រូវបានលើកស្ទួយ ដោយអន្តរាគមន៍របស់អង្គការសង្គមស៊ីវិលឱ្យទៅជាសមូហភាពថ្មីមួយ ។ សមាគមដែលមានមូលដ្ឋាននៅសហគមន៍ទាំងនេះមានបំណង ផ្លាស់ប្តូរពីរបៀបបែបបុរាណរបស់ខ្លួនឱ្យទៅជាសមាគម ដែលដើរតួបែបទាន់សម័យ ។

តម្រូវការដែលកើនឡើងសម្រាប់ការគ្រប់គ្រងមូលដ្ឋាន តាមរយៈបញ្ញត្តិទាំងឡាយនៃច្បាប់ និង រដ្ឋធម្មនុញ្ញជាតិ សម្រាប់ការផ្តល់អំណាច និង វិមជ្ឈការ បានអូសទាញក្រុមជនតំបន់មូលដ្ឋាន ក្រុមជនក្រៅផ្លូវការ និងសមាគមនានាទាំងនោះ ឱ្យចូលមកក្នុងតួនាទីដ៏សកម្ម ។ សមាគមដែលមានមូលដ្ឋាននៅសហគមន៍ ទាំងនោះបានដើរតួនាទីជាគន្លឹះ សំខាន់ក្នុងការគាំទ្រភាពជាអ្នកដឹកនាំរបស់ស្ត្រី របស់ក្រុមជនរស់នៅតាមជ្រលងភ្នំ និង របស់ក្រុមកុលសម្ព័ន្ធ ក្នុងស្ថាប័ន **ផាន់ឆាយាទី រ៉ាជ** និង ក្នុង **ស្ថាប័ននៅតំបន់ប្រជុំជន** ប្រទេសឥណ្ឌា ។ ការជួយជ្រោមជ្រែងរបស់ពួកគេ បានពង្រឹងការទទួលខុសត្រូវសម្រាប់ការជ្រើសរើសតំណាងតាមមូលដ្ឋាន ដូចជាការគាំទ្រដែលកាន់តែមានតម្លាភាព និងការចូលរួមបែបប្រជាធិបតេយ្យ ដែលកើតមានក្នុងការបំពេញតួនាទី តាមបែបផែននៃការដឹកនាំថ្មី ។

ក្នុងឆ្នាំថ្មីៗនេះ គេឃើញមានការកើនឡើងជាក់ស្តែង នៃតួនាទីរបស់សង្គមស៊ីវិល ក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ សមាគមមូលដ្ឋានតូចៗមិនផ្លូវការនិងអង្គភាពជាសម្ព័ន្ធភាពរបស់ពួកគេ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកែប្រែគោលនយោបាយ និង ការអនុវត្ត ពីចំណុចជាគោលជំហររបស់ជនក្រីក្រ និង ជនដែលត្រូវបានគេផាត់ឃ្លាតឆ្ងាយពីសង្គម ។ ផលប្រយោជន៍នៃក្រុមជនខ្វះអភ័យឯកសិទ្ធិ បានស្ថិតនៅមិនទាន់មានការយកចិត្តទុកដាក់ក្នុងចរន្តច្បាស់លាស់នៅឡើយ ហើយបញ្ហានេះ ទាល់តែមានការផ្តើមគំនិតរៀបចំ និងផ្តល់អំណាចដល់ពួកគេ ឱ្យបានទៅជាក្រុមសមូហភាព ហើយក្តីកង្វល់របស់ពួកគេចំពោះរដ្ឋ ត្រូវបានគេលើកមកគិតគូរដោះស្រាយ ។

ប្រជាពលរដ្ឋតែងតែមានលទ្ធភាពធ្វើសកម្មភាពបានយ៉ាងច្រើន ពេលដែលពួកគេស្ថិតក្នុងភាពប្រមូលផ្តុំជាសមូហភាពមួយ ។ ការរៀបចំជាក្រុមអ្នកក្បែរខាងគ្នា ជាសហជីពមូលដ្ឋាន ជាក្រុមយុវជន ជាគណៈកម្មាធិការភូមិ គឺជាឧទាហរណ៍នៃប្រភេទប្រមូលផ្តុំជាសមូលភាពទាំងនោះ ។ បុគ្គលដែលបានចូលរួមមកជាមួយក្រុមប្រមូលផ្តុំជាសមូហភាពនោះ គឺជាអ្នកអាចទទួលបាននូវព័ត៌មាន ជាអ្នកដែលបានទទួលបទពិសោធន៍ក្នុងការចូលរួមក្នុងអង្គការនានា ហើយគេមានលទ្ធភាពធ្វើឱ្យមាននិរន្តរភាពនូវការសន្យាទទួលកិច្ចការណាមួយ និងគេអាចមានភាពជាជនសកម្ម។

ស្ថាប័ននានានៅគ្រប់កម្រិតមានការពាក់ព័ន្ធច្រើនជាង កិច្ចខិតខំប្រឹងប្រែងសុទ្ធដែលអនុវត្តដោយបុគ្គល ។ ស្ថាប័នទាំងនោះ បានបង្ហាញនូវ " សកម្មភាពប្រមូលផ្តុំជាសមូហភាព " ដែលក្នុងនោះ ផលប្រយោជន៍ ធនធាន និងគំនិតទាំងឡាយរបស់ជនជាច្រើន បាននាំមកចូលរួមជាមួយគ្នា... ។ ជាមួយគ្នានេះ ផលចំណេញ ដែលបានមកពីស្ថាប័នទាំងឡាយ បានមានទំនោរទៅជា" ផលប្រយោជន៍សាធារណៈ " ដែលមានគុណតម្លៃ ចំពោះមនុស្សក្រៅពីអ្នកដែលបានចូលរួមដោយផ្ទាល់ក្នុងសកម្មភាពនោះ ។

ការរីកលូតលាស់ប្រជាតិបតេយ្យនៃទំនាក់ទំនងឥទ្ធិពលប្រពៃណីបូរាណក្នុងសង្គមស៊ីវិល និងបរាជ័យក្នុងការធ្វើឱ្យមានមូលដ្ឋានជាសន្និទានភាព (លក្ខណៈសមហេតុផលតាមរបបក្រុម) ដើម្បីបង្កើតនូវការដឹកនាំថ្មីតាមរយៈស្ថាប័ននយោបាយផ្លូវការ បានស្ថិតនៅក្នុងបេះដូងនៃអាជ្ញាធរដែលកើតឡើងដោយគ្មានអ្នកណាគ្រប់គ្រងក្នុងរបបនយោបាយឥណ្ឋា ។ នេះជាកន្លែងនៃភាពជាអ្នកដឹកនាំ ដែលពលរដ្ឋអាចមើលឃើញ អាចបង្កើត ឱ្យមានគំនិតខុសគ្នា ។ សកម្មជនរបស់ពលរដ្ឋអាចសង់ស្ពានរវាងពលរដ្ឋ និង រដ្ឋ ។ ភាពជាអ្នកដឹកនាំរបស់ពលរដ្ឋបានអនុវត្ត នៅពេលដែលពួកគេកសាងសង្គម ហើយធ្វើឱ្យការគ្រប់គ្រងរបស់ពួកគេរីកចំរើន ។ ការទទួលស្គាល់លទ្ធភាព ដែលមើលឃើញ និង ការលើកស្ទួយភាពជាអ្នកដឹកនាំរបស់ពលរដ្ឋ ជាគន្លឹះសម្រាប់បញ្ហានេះ ។

ភាពជាអ្នកដឹកនាំរបស់ពលរដ្ឋ ត្រូវបានអនុវត្ត ពេលដែលពួកគេជំរុញឱ្យពលរដ្ឋដទៃទៀត ធ្វើសកម្មភាព ពេលដែលពួកគេលើកទឹកចិត្តពលរដ្ឋឱ្យសកម្ម ក្នុងសង្គម និង នយោបាយ ( កូលី ១៩៩១) ។

## ការយល់ដឹងពីភាពជាពលរដ្ឋ និង ភាពជាអ្នកដឹកនាំពលរដ្ឋ

ពាក្យថា "ភាពជាពលរដ្ឋ" ត្រូវបានពិភាក្សា ឱ្យនិយមន័យ ហើយបានយល់ ត្រង់ចំណុចពេលវេលាខុសៗគ្នា នៅក្នុងប្រវត្តិសាស្ត្រនយោបាយ ។ និយមន័យមួយនោះ អាចយល់ពីប្រពៃណីផ្សេងៗគ្នា ក្នុងភាពជាពលរដ្ឋ ដែលមានគំនិតចេញមកតាមរយៈការនិយាយស្តី ។ ខណៈដែលគំនិតទាំងនេះ បានបន្ថែមឱ្យមានគំនិតនានា អ្នកផ្សេងទៀតបានផ្តល់ឱ្យនូវភាពជាប់ទាក់ទងនឹងគំនិតបែកខ្ញែកខុសគ្នា ។ គំនិតបែកខ្ញែកខុសគ្នាទាំងនេះ ច្រើនតែជាពេលវេលាដែលប្រកួតប្រជែងគ្នាទៅវិញទៅមក ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ នៅពេលផ្តល់និយមន័យទៅលើ **ភាពជាពលរដ្ឋ** ។ នេះគឺជាការពិតដ៏ពិសេសមួយ នៅក្នុងបរិបទប្រទេសឥណ្ឌា ។

ចំពោះប្រទេសប៉ែកខាងលិច បរិបទ **ភាពជាពលរដ្ឋ** ផ្តោតទៅលើការជ្រើសរើសរបស់បុគ្គល ។ ពាក្យ នេះ ត្រូវបានបានពិចារណាថា បុគ្គលធ្វើសកម្មភាពប្រកបដោយសន្និទានភាព (ភាពសមហេតុផលតាមរបបរបស់ក្រុម) ដើម្បីឱ្យមានការរីកចម្រើនដល់ផលប្រយោជន៍របស់ពួកគេក្នុងសង្គម ។ ការផ្តោតទៅលើការជ្រើសរើសរបស់បុគ្គលនេះ បានពឹងផ្អែកលើជំនឿដែលរដ្ឋនឹងផ្តល់ការការពារដ៏ចាំបាច់ និងផ្តល់ឱ្យមានសុខុមាលភាព ក្នុងការអនុវត្តការជ្រើសរើសរបស់បុគ្គល ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនត្រូវបានទទួលស្គាល់នូវហេតុការណ៍ពិត ដែលការជ្រើសរើសរបស់បុគ្គល ត្រូវបានកំណត់ដោយវិសមភាពទាក់ទងនឹងរចនាសម្ព័ន្ធនៅក្នុងសង្គម ។ នៅក្នុងបរិបទឥណ្ឌាការជ្រើសរើសរបស់បុគ្គល ត្រូវបានដាក់លក្ខខណ្ឌផងដែរ ដោយការជ្រើសរើសជាសមូហភាព របស់សហគមន៍ ។ ក្នុងសង្គមមួយប្រកបដោយឋានានុក្រម ការជ្រើសរើស និង ផលប្រយោជន៍នៃអ្នកមានអំណាច គឺតែងតែត្រូវបានគ្រោងឡើងបែបជាការជ្រើសរើសនៃសហគមន៍សមូហភាព ។ គឺជាជំនឿខុសឆ្គងរបស់សហគមន៍ ។ នៅក្នុងបរិបទឥណ្ឌា សហគមន៍ និងបុគ្គលត្រូវបានយកចិត្តទុកដាក់ទាំងអស់គ្នា ។ ការរស់នៅជាសហគមន៍សមូហភាពគឺជាផ្នែកមួយនៃការរស់នៅរបស់បុគ្គលផងដែរ ។ ជាសមាជិកក្នុងសង្គម មនុស្សម្នាក់ គួរបង្កើតនូវលក្ខខណ្ឌ និង កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍខ្លួនឯង ព្រមទាំងដើម្បីផលប្រយោជន៍រួម និង សម្រាប់សុខុមាលភាពរបស់សហគមន៍ទាំងមូល ជាមួយនឹងការផ្តោតសំខាន់ចំពោះជនក្រីក្រ និង ជនដែលត្រូវបានផាត់ចេញឃ្លាតឆ្ងាយពីសង្គម ។

សិទ្ធិ និង កាតព្វកិច្ច ស្ថិតនៅជាស្នូល នៃ **ភាពជាពលរដ្ឋ** ។ **ភាពជាពលរដ្ឋ** គឺជា "សិទ្ធិ" ដែលគេយល់ថា ជាលក្ខខណ្ឌផ្លូវការ ដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋ ។ បុគ្គលម្នាក់ត្រូវបានផ្តល់អំណាច ដើម្បីបញ្ជាក់ឱ្យច្បាស់ ពីសិទ្ធិជាសកលដែលបានដាក់ចូលក្នុងច្បាប់ ។ ភាពជាពលរដ្ឋ គឺ "កាតព្វកិច្ច" ដែលគេយល់ថា ជាការចូលរួមក្នុងនយោបាយជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ។

សិទ្ធិត្រូវបានគិតថា ជាសិទ្ធិ *នយោបាយ* (ឧទាហរណ៍ : សិទ្ធិបោះឆ្នោត សិទ្ធិបង្កើតសមាគមន៍ )ជាសិទ្ធិ *ស៊ីវិល* (សេរីភាពនៃការបញ្ចេញមតិ សេរីភាពរបស់មនុស្ស)ជាសិទ្ធិ *សង្គម* (មិនមានការរើសអើង វណ្ណៈ ឋានៈ សាសនា ឬ ភេទ និង សិទ្ធិទទួលបានស្មើគ្នាជាមូលដ្ឋាន ដូចជា សុខភាព ការអប់រំ ...) ជាសិទ្ធិ *សេដ្ឋកិច្ច* (ការការពារទ្រព្យសម្បត្តិឯកជន ការទទួលបានការងារស្មើគ្នា និង ធនធានក្នុងការរស់នៅ) និងជាសិទ្ធិ *វប្បធម៌* (ការការពារ និង ការអភិរក្សនៃប្រពៃណីវប្បធម៌) ។ វាគឺជាបញ្ហានៃការជ្រើសរើសសម្រាប់បុគ្គល ដើម្បីទាមទារ និង អនុវត្តសិទ្ធិរបស់ខ្លួន។ ចំណុចមួយចំនួនបានបញ្ជាក់នៅក្នុងច្បាប់ ហើយ ចំណុចផ្សេងៗទៀតមិនបានបញ្ជាក់ទេ ។ ការដឹកនាំរដ្ឋ គឺជាការការពារប្រជាពលរដ្ឋ ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ។ មនុស្សជាច្រើនបានយល់ថា វាមិនទាន់គ្រប់គ្រាន់នោះទេ ។ ការអនុវត្តការជ្រើសរើស និង ការទាមទារសិទ្ធិ ត្រូវការធនធាន អំណាច និង ចំណេះដឹង ។ សិទ្ធិក្នុងការការពារទ្រព្យសម្បត្តិ និង សិទ្ធិក្នុងការរស់នៅ មានន័យដ៏តូច ក្នុងសិទ្ធិទាមទារនូវធនធាន អំណាច និង ចំណេះដឹងគ្រប់គ្រាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងផលប្រយោជន៍ប្រកបអ្នកមានអំណាច ក្នុងវេទិកានយោបាយផ្លូវការ ។ ករណីនេះ គឺជាករណីពិសេស នៅពេលដែលផលប្រយោជន៍អ្នកមានអំណាច បាន គូសបង្ហាញថាជា "ផលប្រយោជន៍រួម" តទល់គ្នានឹង "ផលប្រយោជន៍បុគ្គល" នៃម្ចាស់ដី និងសមាជិក នៃ សហគមន៍ ។

ស្ថាប័ន ឬ មនុស្សដែលប្រឆាំង នឹងអ្នកដែលទាមទារសិទ្ធិ តែងមានឥទ្ធិពលដល់លទ្ធផលនៃការទាមទារសិទ្ធិ ។ ដូច្នេះ ផ្នែកផ្សេងទៀតនៃសិទ្ធិ គឺជាកាតព្វកិច្ច ដែលឆ្លើយតប ហើយត្រូវបានទុកជាប្រយោជន៍ ។ ចាប់តាំងពីដំណើរការទាមទារសិទ្ធិ បានជាប់ទាក់ទងនឹងនយោបាយ ហើយត្រូវបានសម្តែងចេញមកក្រៅ ដោយការតស៊ូរវាងអ្នកទទួលផលប្រយោជន៍ អ្នកមានអំណាច និង អ្នកមានចំណេះដឹងផ្សេងៗគ្នា ជនក្រីក្រ និងជនដែលត្រូវបានផាត់ឃ្លាតឆ្ងាយពីសង្គម ដែលពុំមានផលប្រយោជន៍ទាល់តែសោះ ក្នុងទំនាក់ទំនងនៃអំណាច និង ធនធានទាំងនេះ យ៉ាងហោច បីដូចជាមនសិការ ផ្តល់លទ្ធភាពបញ្ចូលការទាមទាររបស់គេ ទៅជា សិទ្ធិរបស់គេ។

ខណៈដែល **ភាពជាពលរដ្ឋ** ផ្តល់អំណាចឱ្យមនុស្សម្នាក់ដោយរដ្ឋ នៅក្នុងប្រជាធិបតេយ្យ រៀបចំធ្វើឱ្យរដ្ឋពង្វាងផ្លូវភាពស្របទៅតាមច្បាប់របស់ខ្លួនដែលបានពីពលរដ្ឋ ដែលបានស្ម័គ្រចិត្តផ្តល់ឱ្យពួកគេបានឈរដឹកនាំ តាម

រយៈការបោះឆ្នោតរើសតំណាងរបស់ពួកគេ ហើយបើពលរដ្ឋបានបដិសេធជាសមូហភាព ក្នុងការផ្តល់ភាពស្របច្បាប់រដ្ឋនោះ ពួកគេនឹងបាត់អត្តសញ្ញាណជារដ្ឋ ។ ដូចនេះ វាតែងតែមានទំនាក់ទំនងរវាងពលរដ្ឋ និង រដ្ឋ។

រដ្ឋអាចឱ្យនិយមន័យជាប្រជាពលរដ្ឋ ដែលរៀបចំសម្រាប់ការគ្រប់គ្រងក្នុងភូមិសាស្ត្រទឹកដីកំណត់ ។ ជាតិ មួយ គឺជារាងកាយរបស់មនុស្ស ដែលបានកាន់កាប់នូវអត្តសញ្ញាណ ក្នុងឃុំមួយ ប្រកបដោយការចែករំលែកគ្នានូវប្រពៃណីប្រវត្តិសាស្ត្រ ធាតុសំខាន់ៗក្នុងវប្បធម៌រួម និងភាពសមាមាត្រដ៏ត្រឹមត្រូវរបស់ពួកគេ ក្នុងការតាំងលំនៅក្នុងភូមិសាស្ត្រដ៏ជាក់លាក់មួយ ។ រដ្ឋនៃជាតិមួយតែងពិពណ៌នានូវបរិបទមួយ ដែលក្នុងនោះតំបន់ភូមិសាស្ត្រទាំងមូល ដែលជាស្រុកកំណើត សម្រាប់ប្រជាពលរដ្ឋ បង្ហាញអត្តសញ្ញាណរបស់ខ្លួន ជាសហគមន៍ ព្រោះគេមានវប្បធម៌ ប្រវត្តិសាស្ត្រ និង ភាសាដែលត្រូវចែករំលែក រួមទាំងអត្តចរិតបែបជនជាតិភាគតិច ហើយដែលត្រូវបានគ្រប់គ្រងដោយប្រព័ន្ធនយោបាយមួយ ។ រដ្ឋដែលទំនើបត្រូវកំណត់ព្រំដែនរបស់ខ្លួន ។ យើងជាសមាជិករបស់រដ្ឋ រស់នៅក្នុងទឹកដីដែលយើងកើត ហើយយើងអាចផ្លាស់ប្តូរការរស់នៅរបស់យើង ទៅនៅរដ្ឋផ្សេងដោយស្វាមីភក្តិ ឬក៏ផ្លាស់ប្តូរសញ្ជាតិ ដោយមានការអនុញ្ញាត បញ្ជាក់ពីរដ្ឋ ដែលយើងមានបំណងនោះ។

សង្ខេបមក យើងអាចនិយាយបានថា **ភាពជាពលរដ្ឋ** មានន័យថា " ភាពជាសមាជិកនៅក្នុងសហគមន៍មួយ " ។ ភាពជាសមាជិកតម្រូវឱ្យមានការចូលរួម ដោយបុគ្គលក្នុងការកំណត់ និង ដាក់លក្ខខណ្ឌទំនាក់ទនងរបស់ពួកគេ ដោយគ្មានការរើសអើងលើការប្រកាន់វណ្ណៈ ជនជាតិ សាសនា ឬ ភេទ ។ ភាពជាពលរដ្ឋគឺសំដៅលើការដឹកនាំពលរដ្ឋ ដោយបង្ហាញពីលទ្ធភាព នៃអារម្មណ៍ ដែលមានបំណងចូលរួមជាមួយរដ្ឋ ។ **ភាពជាពលរដ្ឋ** គឺជាការបំពត់ខ្លួនតាមអត្តសញ្ញាណពលរដ្ឋផ្តល់ឱ្យដោយរដ្ឋ ហើយដែលបង្កើតខ្លឹមសារនៃកម្មសិទ្ធិជូនទៅរដ្ឋឬជាតិនោះ ។ **ភាពជាពលរដ្ឋ** គឺជាលក្ខខន្តិកៈ ដែលផ្តល់ឱ្យចំពោះបុគ្គលនូវសិទ្ធិស្មើគ្នា និងកាតព្វកិច្ចសេរីភាព ការបង្ខិតបង្ខំ អំណាច និង ការទទួលខុសត្រូវ ។ **ភាពជាពលរដ្ឋ** តែងតែជាបញ្ហារបស់សហគមន៍មួយ ។ ក្នុងន័យនេះ ប្រជាពលរដ្ឋតែងតែមានការសហការរវាងគ្នា រវាងអ្នកដែលរស់នៅជាមួយអ្នកដទៃ... ។ ប្រជាពលរដ្ឋរស់នៅក្នុងសង្គមប្រជាធិបតេយ្យ ជាមនុស្សដែលមានសិទ្ធិ និង តួនាទី ។ សិទ្ធិចម្បង គឺថា ការបង្កើតច្បាប់ និងតួនាទីក្នុងការគោរពច្បាប់ ។

ពលរដ្ឋម្នាក់ អាចត្រូវចាត់ទុកជាមនុស្សម្នាក់ ដែលអាស្រ័យផលនៃសិទ្ធិសង្គម នយោបាយ ស៊ីវិលសេដ្ឋកិច្ច និង វប្បធម៌ ដែលជាផ្នែកមួយនៃជាតិ-រដ្ឋ និងសង្គមមួយ ដែលមានសិទ្ធិ និង តួនាទីច្បាស់លាស់ ។ ពលរដ្ឋសកម្មគួរតែដឹងអំពីការពិតជាក់ស្តែង មានឆន្ទៈធ្វើការផ្លាស់ប្តូរការពិតជាក់ស្តែង និងខិតខំចំពោះផលប្រយោជន៍សាធារណៈរួម ហើយលើកស្ទួយ ការខិតខំប្រឹងប្រែងជាសមូហភាព នៅក្នុងសហគមន៍របស់ខ្លួន ។

ភាពជាអ្នកដឹកនាំ នៅក្នុងបរិបទសហគន៏ អាចយល់បានពីដំណើរការនៃឥទ្ធិពល និង ការលើកទឹកចិត្ត ប្រជាពលរដ្ឋ ដើម្បីនាំមកនូវការផ្លាស់ប្តូរសង្គមប្រកបវិជ្ជមាន ជាគុណប្រយោជន៏ ចំពោះផ្នែកនៃជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ។ ភាពជាអ្នកដឹកនាំ ជាគុណភាពមនុស្សធមិនិយម តាមរយៈអ្វីដែលមនុស្សម្នាក់បានព្យាយាមបំពេញតម្រូវការរបស់សហគមន៏ ដោយនាំមកនូវកិច្ចសហការរបស់ខ្លួន និង ដោយបង្កើតនូវភាពទុកចិត្ត ។ អ្នកដឹកនាំពលរដ្ឋម្នាក់ គឺជាបុគ្គលដែលមានសមត្ថភាពធ្វើជាតំណាង ផ្តល់ទិសដៅ និងស្វែងរកការទទួលយកផ្នែក ឬ ក្រុមសំខាន់ៗ ។ម្យ៉ាងវិញទៀត អ្នកដឹកនាំមានទិសដៅ ថាមពលចាំបាច់ និងសមត្ថភាពបង្កើតអានុភាពធ្វើឱ្យសម្រេចនូវផលប្រយោជន៏សាធារណៈ (ការផ្លាស់ប្តូរសង្គមដែលចង់បាន) ។ ដូច្នេះ ក្នុងដំណើរការលើកស្ទួយអ្នកដឹកនាំពលរដ្ឋ ចរិយាសម្បត្តិនៃភាពជាពលរដ្ឋ និង ភាពជាអ្នកដឹកនាំ ត្រូវបានពិចារណារួមគ្នា ។ អ្នកដឹកនាំពលរដ្ឋល្អ គួរជាពលរដ្ឋសកម្ម ហើយមានសមត្ថភាពរែកពុនការទទួលខុសត្រូវ ។

ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំបុគ្គល និងសមូហភាព មានលក្ខណៈជាវិចារវិទ្យា (បែបការគិតពិចារណា) ជាងបែបឋានានុក្រម(បែបចាត់តាំង) ។សមូហកម្មផ្តល់លទ្ធភាពឱ្យមានការអប់រំ ហើយផ្តល់មូលដ្ឋានសម្រាប់ធានាការទទួលខុសត្រូវសាធារណៈ នៃភាពជាអ្នកដឹកនាំ ។ វាបានកំណត់នូវការធ្វើការសម្រេចចិត្តដែលមានលក្ខណៈតម្លាភាព និងប្រជាធិបតេយ្យ នៅក្នុងទំនាក់ទំនងសមូហភាព អប់រំ អន្តរបុគ្គល និងអន្តរសមាគមដោយចែករំលែកធនធានដែលបានកៀងគរនិងការប្រើប្រាស់បែបណា ព្រមទាំងការវាយតម្លៃការអនុវត្តក្នុងទំនាក់ទំនង ដើម្បីថ្លែងវត្ថុបំណងនៃសមូហភាព ។ ភាពជាអ្នកដឹកនាំ ត្រូវពិនិត្យថាជាដំណើរការអន្តរកម្ម ជាមួយនឹងការយកចិត្តទុកដាក់លើការជួយអន្តរាគមន៏អំពីសមត្ថភាព ។ វាបានកំណត់ថា ភាពជាអ្នកដឹកនាំ ត្រូវតែដើរតួជាគន្លឹះសំខាន់ នាំមកនូវធនធានបន្ថែម (ព័ត៌មាន សម្ភារ កិច្ចជំនាញ ទុន...។ល។) ដែលបានមកពីភ្នាក់ងារខាងក្រៅ ហើយធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានដែលមានខាងក្នុង ។ វាមានន័យដែរថាគឺធានាការចូលរួមរបស់បុគ្គលនានា និងក្រុមដែលទទួលបានផលប្រយោជន៏ផ្សេងៗគ្នា នៅក្នុងសមូហភាព។

អ្នកដឹកនាំពលរដ្ឋត្រូវបានគេរំពឹងថានឹងដើរតួនាទីច្រើនផ្នែកៗ ។ ទោះបីជាយ៉ាងណា តួនាទី ២ បែបដូចតទៅនេះ មានសារៈសំខាន់ជាចម្បង។

## ១- ការកសាងសង្គម

មុខងារសំខាន់ទី ១ របស់អ្នកដឹកនាំពលរដ្ឋ គឺកសាងសង្គមមួយ ដែលលើកស្ទួយបទដ្ឋាន និង គុណតម្លៃទាក់ទងនឹងការរស់នៅរួមគ្នា និងចូលរួមទាំងអស់គ្នា ។ អ្នកដឹកនាំពលរដ្ឋត្រូវតែប្រាថ្នាសង្គមមួយ ដែល លើកកម្ពស់

យុត្តិធម៌សមភាពដល់ពលរដ្ឋទាំងអស់ ។ សង្គមមួយមិនត្រូវអនុញ្ញាតឱ្យមនុស្សណាម្នាក់ទទួលការរើសអើង លើការប្រកាន់វណ្ណៈ ឋានៈ សាសនា និង ភេទ ឬ អាយុឡើយ ។ សង្គមមួយអាចសម្រេចបាននោះ លុះត្រាតែអ្នកដឹកនាំពលរដ្ឋបំពេញនូវមុខងារសំខាន់បី ។

**ក. សម្របសម្រួលការកៀងគរក្នុងសង្គម**

វារួមបញ្ចូលទាំងការកៀងគរជនក្រីក្រ និងជនដែលត្រូវគេផាត់ឃ្លាតឆ្ងាយពីសង្គម ដើម្បីធ្វើកិច្ចការសមូហភាព ។ កិច្ចការបុគ្គលមានសារៈសំខាន់ក្នុងសង្គម ទោះបីជាយ៉ាងណាក៏ដោយ វានៅតែមានអារម្មណ៍ថា មិនមានអំណាច ចំពោះមុខផលប្រយោជន៍របស់អ្នកមានអំណាច នៃផ្នែកដែលមានអត្ថប្រយោជន៍ក្នុងសង្គម ។ កិច្ចការសមូហភាព និង ការផ្តល់អំណាចសមូហភាព ជាឧបករណ៍ដែលមានអំណាចក្នុងការផ្លាស់ប្តូរភាពខុសៗគ្នា នៃរចនាសម្ព័ន្ធជាគ្រឹះ ផ្លាស់ប្តូរអយុត្តិធម៌ និងផ្លាស់ប្តូរភាពរើសអើងនៅក្នុងសង្គម ។ គោលបំណង នៃការកៀងគរសង្គម និង កិច្ចការសមូហភាព ដែលអាចរៀបចំពីសន្ទ្យាក្នុងការងារស្ថាបនាជួយខ្លួនឯងនៅក្នុងភូមិ ឬ អ្នកក្បែរខាង (ដូចជា ការសាងសងផ្លូវថ្នល់ និង ការសំអាតស្រះ ) ដែលបានអនុវត្តសិទ្ធិលើធនធានធម្មជាតិ (ដូចជា ការ ការពារព្រៃឈើ ឬ ធនធានជាកម្មសិទ្ធិរួម ) ទៅជាសកម្មភាពតវ៉ាទ្រង់ទ្រាយធំ (ដូចជាការតវ៉ា ការទទួលបានដីធ្លីកសិកម្ម) ។

**ខ- ការជំនះមិនឱ្យមានការផាត់ចេញអ្នកណាម្នាក់ពីសង្គម**

សង្គមក្នុងទម្រង់បច្ចុប្បន្នរបស់ខ្លួន គឺជាសង្គមដែលប្រណាំងប្រជែង និងប្រកបដោយឋានានុក្រម ។ វិសមភាព បែបរចនាសម្ព័ន្ធ (បែបការរៀបចំឱ្យមាន) និងបែបផ្សេងទៀតលើវណ្ណៈ ឋានៈ ជនជាតិ សាសនា ភេទ និង អាយុ បង្កឱ្យកើតមានការផាត់ក្ខាឃ្លាតពីសង្គម ។ ធនធាន ចំណេះដឹង និង កាលានុវត្តភាពក្នុងសង្គមអានុភាព ត្រូវបានបដិសេធ ចំពោះជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ។ មុខងារមួយនៃអ្នកដឹកនាំពលរដ្ឋ គឺត្រូវសម្រួលឱ្យជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ឱ្យទទួលបានធនធាន ចំណេះដឹង និង កាលានុវត្តភាពនោះ ។

**គ-ការគ្រប់គ្រងផ្នែកសង្គមដែលខុសៗគ្នា /ក្រុមដែលត្រូវបានបែងចែកខុសៗគ្នា**

នៅក្នុងភាពចំរុះនៃសង្គមប្រជាធិបតេយ្យ គួរគប្បីដឹងថាប្រជាពលរដ្ឋមានទ្រព្យសម្បត្តិ ។ ទោះបីជាយ៉ាងណាក៏ដោយ ពេលសង្គមត្រូវបែងចែកជាជាន់ថ្នាក់នៃឋានានុក្រម វាអាចឈានទៅរកការរើសអើង ប្រឆាំងទៅនឹងការកេងប្រវ័ញ្ចលើជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ដែលស្ថិតនៅជាន់ក្រោមនៃឋានានុក្រម ។ ទំនាស់នៃករណីទាំងពីរនេះ ជុំវិញផលប្រយោជន៍ និង អាទិភាពតែងជៀសមិនផុត ។ មុខងារមួយ របស់អ្នកដឹកនាំពលរដ្ឋ គឺត្រូវគ្រប់គ្រង និង ដោះស្រាយទំនាស់

ទាំងនេះ ក្នុងសហគមន៍ ដោយឆ្លងកាត់ការចរចា និងយោបល់ឯកភាព (កុងសង់ស៊ុស) ។ អ្នកដឹកនាំពលរដ្ឋ ត្រូវតែដឹងខ្លួនខ្លះថា ត្រូវស្វែងយល់ថា ជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម មានអារម្មណ៍ថា គេគ្មានអំណាច ក្នុងស្ថានភាពទំនាស់បែបនេះ រហូតមានដំណើរការសម្របសម្រួលមួយជាចំហ ជួយឱ្យផលប្រយោជន៍របស់ពួកគេបានលេចឡើង ។

## ២-ការចូលរួមខ្ជាប់ខ្ជួននៃស្ថាប័នអភិបាលកិច្ច

អភិបាលកិច្ច ត្រូវបានកំណត់និយមន័យថាជារចនាសម្ព័ន្ធ និង ដំណើរការសម្រេចចិត្តសាធារណៈ សម្រាប់កៀងគរធនធានសាធារណៈ ដើម្បីផលប្រយោជន៍សាធារណៈ ដូចជា សុខភាព ការអប់រំ ទឹកស្អាត និង សេវានៃគ្រឿងឧបភោគ-បរិភោគដទៃទៀត ។ ស្ថាប័នសាធារណៈជាច្រើនមានការទទួលខុសត្រូវដើម្បីសម្រេចចិត្តទាក់ទងនឹងមុខងារអភិបាលកិច្ចនៃសង្គមមួយ ។ អ្នកដឹកនាំពលរដ្ឋត្រូវតែដឹងពីស្ថាប័នសាធារណៈ ហើយ សម្រេចចិត្តបែបណា ទាក់ទងនឹងផលប្រយោជន៍រួមសាធារណៈ ដែលមានឥទ្ធិពលដល់ការរស់នៅរបស់ពលរដ្ឋ ។ ពួកគេ គួរមិនត្រឹមតែដឹងពីរចនាសម្ព័ន្ធ និង ដំណើរការទាំងនោះទេ ប៉ុន្តែ ពួកគេគួរសន្សំយ៉ាងសកម្មផងដែរ ក្នុងការសម្រេចចិត្ត ដូចជា នៅពេលគ្រប់គ្រងផលប្រយោជន៍នៃជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម។ អ្នកដឹកនាំពលរដ្ឋអាចចូលរួមខ្ជាប់ខ្ជួនក្នុងស្ថាប័នអភិបាលកិច្ចក្នុងវិធី ៣ ខាងដូចតទៅ :

### ក-ការបំពងសំឡេង

ជាច្រើនជំនាន់ ជនដែលមានអំណាចក្នុងសង្គម សង្កត់សង្កិនសំឡេងរបស់ជនក្រីក្រ និង ជនដែលត្រូវផាត់ ឃ្លាតឆ្ងាយពីសង្គម ។ ក្នុងគោលបំណងឱ្យស្ថាប័នអភិបាលកិច្ច ឆ្លើយតបនិងតម្រូវការ និង បំណងប្រាថ្នា របស់ជនរស់នៅតាមជ្រលងភ្នំ ក្រុមកុលសម្ព័ន្ធ ស្ត្រី កុមារ និង ជនពិការ សំឡេងរបស់ពួកគេត្រូវបានកៀងគរ រហូតអាចឮដល់អ្នកធ្វើការសម្រេចចិត្ត ។ អ្នកដឹកនាំពលរដ្ឋគួរតែមានលទ្ធភាព បំពងនូវសំឡេងសមូហភាព នៃជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គមទាំងនេះ ដើម្បី ឱ្យពួកគេបានទទួល និង ត្រួតពិនិត្យធនធាន ដែលគាំទ្រការរស់នៅរបស់ពួកគេ ដើម្បី ឱ្យទទួលបានយុត្តិធម៌ និង សេវាសង្គម។

### ខ- ការចូលរួមខ្ជាប់ខ្ជួនក្នុងការចរចា

ក្នុងគោលបំណងនាំមកនូវការផ្លាស់ប្តូរក្នុងសង្គម ការផ្លាស់ប្តូរក្នុងទំនាក់ទំនងអំណាចគ្រឹះ ដាច់ខាត ត្រូវតែមានជាចាំបាច់ ។ លទ្ធផលនៃការអភិវឌ្ឍដែលប៉ងប្រាថ្នា មិនអាចទទួលបានជោគជ័យ ដោយគ្មានការផ្លាស់ប្តូរ អំណាចដែលខុសគ្នាក្នុងសង្គម រវាងជនរស់នៅតាមជ្រលងភ្នំនិងជន មិនមែនរស់

នៅតាមជ្រលងភ្នំ ក្រុមកុលសម្ព័ន្ធនិងមិនមែនកុលសម្ព័ន្ធ ឬ ស្ត្រីនិងបុរស ។ លទ្ធផលនៃការអភិវឌ្ឍ មិនអាចមាននិរន្តរភាពបានទេ ជាមួយភាពឃ្លាតគ្នារវាង " **មាន** " និង " **គ្មាន** " នោះ ។ ការផ្លាស់ប្តូរទំនាក់ទំនងអំណាចដែលមាន ត្រូវទាមទារនូវដំណើរការ នៃការចរចាររវាងពីរភាគី ។ បទពិសោធបានបង្ហាញថា ការសម្របសម្រួលចំហខាងក្រៅ តែងតែជួយជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គមក្នុងការចរចាបែបនោះ ជាមួយនឹងការមើលទៅរកការផ្លាស់ប្តូរ ទំនាក់ទំនងអំណាច ។ អ្នកដឹកនាំពលរដ្ឋ គួរបំពេញកិច្ចការជាអ្នកសម្របសម្រួលចំហខាងក្រៅ ក្នុងការចរចាបែបនេះ ។ ពួកគេត្រូវលើកទឹកចិត្ត កៀងគរ អប់រំ និងកសាងសមត្ថភាពជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ដើម្បីធ្វើការចរចាជាមួយអ្នកមានអំណាច ។ អ្នកដឹកនាំពលរដ្ឋត្រូវតែយល់ថា ការចរចានយោបាយបែបនេះ តែងជាប់ទាក់ទងនឹងទំនាស់ ។ ដូច្នេះទំនាស់ទាំងនេះត្រូវបានដោះស្រាយ ដោយការសន្យាក្នុងការពិភាក្សា ជាមួយអ្នកមានអំណាច ។

**គ- ការពង្រឹងភាពទុកចិត្ត**

ក្នុងរង្វង់ឆ្នាំនៃការកេងប្រវ័ញ្ច ការបោកប្រាស់ និងការរើសអើង បានបង្កើតឱ្យមានភាពមន្ទិលសង្ស័យ និងភាពអល់ឯកក្នុងចំណោមជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ចំពោះការដឹកនាំនយោបាយ និង ស្ថាប័នអភិបាលកិច្ច ។ ដើម្បីឈ្នះចិត្តប្រជាពលរដ្ឋទាំងនេះ អ្នកដឹកនាំពលរដ្ឋត្រូវតែធ្វើឱ្យមានការទុកចិត្ត នៅក្នុងសហគមន៍ ។ ការជឿទុកចិត្តទាំងនេះ ត្រូវបានធ្វើឱ្យមានតែនៅពេលដែលអ្នកដឹកនាំពលរដ្ឋបានគាំទ្រយ៉ាងសកម្មនូវការតស៊ូរបស់ជនក្រីក្រ និង ជនដែលត្រូវផាត់ឃ្លាតឆ្ងាយពីសង្គម ក្នុងការបំពងសំឡេងរបស់ពួកគេ ក្នុងការចរចាជាមួយអ្នកមានអំណាច ក្នុងការពុះពារជំនះការផាត់ចេញពីសង្គម និងក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើង ព្រមទាំងក្នុងការកៀងគរនូវគំនិតរបស់គេក្នុងដំណើរការសម្រេចចិត្ត និង រចនាសម្ព័ន្ធ ។ អ្នកដឹកនាំពលរដ្ឋ ត្រូវធ្វើឱ្យមានកិត្តិនាមនៅក្នុងសហគមន៍ បីដូចជាថា " ថាអី ធ្វើហ្នឹង " ។

អ្នកដឹកនាំពលរដ្ឋគួរធ្វើឱ្យមានផងដែរនូវកិត្តិនាមល្អ ក្នុងក្រសែភ្នែកនៃអ្នកតំណាងមកពីស្ថានប័នអភិបាលកិច្ច ។ កិត្តិនាមល្អទាំងនេះអាចធ្វើឱ្យបាន តាមរយៈអាកប្បកិរិយារបស់បុគ្គល ដូចជាភាពស្មោះត្រង់ ភាពទៀងទាត់ ភាពម៉ឹងម៉ាត់ច្បាស់លាស់ ការយល់ដឹង និង ការយកចិត្តទុកដាក់ចាប់អារម្មណ៍ ។ អ្នកដឹកនាំពលរដ្ឋ ត្រូវតែមានការទទួលស្គាល់ពីមន្ត្រីនយោបាយ ដោយមានការម៉ឹងម៉ាត់ច្បាស់លាស់ ដែលធ្វើឱ្យគេមើលឃើញថាជា អ្នកដែលមាន ជំនឿស៊ប់ក្នុងការផ្លាស់ប្តូរសង្គម ។

ការកសាងសង្គម និងការគ្រប់គ្រងស្ថាប័នអភិបាលកិច្ចត្រូវមានវដ្ត( មានការវិលផ្លាស់ប្តូរ) នៅក្នុងដំណើរការ ហើយផ្អែកលើចំណេះដឹង អាកប្បកិរិយា និង ជំនាញជាអ្នកដឹកនាំពលរដ្ឋ ។ ដូចច្នេះ ដើម្បីអនុវត្តតួនាទីទាំងនេះ យើងទាមទារបុគ្គលផ្សេងៗគ្នា ឬ ក៏ថា មនុស្សម្នាក់អាចឱ្យអនុវត្តតួនាទីច្រើន ។ បន្ថែមលើនេះ អ្នកដឹកនាំម្នាក់ គួរមានទស្សនវិស័យ ឬទិសដៅច្បាស់លាស់ ឧទាហរណ៍ តើការរៀបចំប្រជុំក្រុមជួយខ្លួនឯង SHGs មានគោលបំណងជាមូលដ្ឋានអ្វី ? តើពួកគេគ្រាន់តែដឹងអត្ថន័យនៃការអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះទេ ឬក៏ពួកគេបានផ្តល់ការពិភាក្សាលើបញ្ហាសង្គមដែលបានកើតឡើងដែរឬទេ? ។ ម្យ៉ាងវិញទៀត តើកិច្ចប្រជុំទាំងនេះត្រូវរៀបចំបែបណា ឱ្យមានការចូលរួម ពីគ្រប់ផ្នែកនៃសង្គម ដូចជាជនពិការ អ្នកមិនទទួលបានអត្ថប្រយោជន៏ (ស្ត្រីមេម៉ាយ អ្នករស់នៅតាមជ្រលងភ្នំ ក្រុមកុលសម្ព័ន្ធ ជនចាស់ជរា ជនជាតិភាគតិច ។ល។) រកឱ្យឃើញលំហសម្រាប់មានសំឡេងនៃគំនិតរបស់ពួកគេ ឱ្យចូលរួមជាមួយដំណើរការកសាងសង្គមនោះ ។

ភាពជាពលរដ្ឋដែលសកម្ម មិនត្រឹមតែពាក់ព័ន្ធជាមួយនិងសិទ្ធិប៉ុណ្ណោះទេ តែត្រូវសន្យាជាមួយនឹងស្ថាប័នសាធារណៈ និង ត្រូវកែប្រែសង្គមផងដែរ ។ ជាមួយនឹងការលើកលែងខ្លះៗ ចំនួនពលរដ្ឋតិចតួចប៉ុណ្ណោះ ដែលបានចូលរួមក្នុងការកសាងសង្គម ឬអញ្ជើញឱ្យចូលរួមក្នុងស្ថាប័នអភិបាលកិច្ច។ ពលរដ្ឋត្រូវបានឮតាមៗគេ ហើយមន្ទិលពីការចូលរួម ឬមានការមន្ទិលសង្ស័យខ្លាំងពីការចូលរួមដោយប្រឹងប្រែងក្នុងការអភិវឌ្ឍ ឬ កំពុង ទាបទារទីតាំងនៃសិទ្ធិរបស់ពួកគេក្នុងអភិបាលកិច្ចស្ថាប័ន ។ នេះគឺជាការពិត ដែលថាមានឧបសគ្គជាច្រើន ស្ថិតនៅជាប់ជាមួយនឹងការចូលរួមរបស់ពលរដ្ឋ ។ ពលរដ្ឋជាច្រើនកំពុងប្រយុទ្ធតទល់នឹងបញ្ហារាល់ថ្ងៃរបស់ពួកគេ ដូចជាភាពក្រីក្រ ជីវភាពរស់នៅ ឬការខ្វះការយល់ដឹង និងព័ត៌មាន ។ ភាពជាពលរដ្ឋដែលសកម្ម អាចយកឈ្នះឧបសគ្គទាំងនេះបាន ។ ជាពិសេសចំពោះក្រុមជនបាត់បង់អត្ថប្រយោជន៏ទាំងស្រុង និងក្រុមជនដែលត្រូវបានផាត់ឃ្លាតឆ្ងាយពីសង្គម ការអនុវត្តភាពជាពលរដ្ឋឱ្យសកម្មបាន នោះទាមទារនូវឱកាសសិក្សាជាប្រព័ន្ធដ៏ច្រើន ដើម្បីបង្កើតនូវទំនុកចិត្ត និងសមត្ថភាពចាំបាច់ ដែលត្រូវបានតម្រូវឱ្យបំពេញតួនាទីនេះមានប្រសិទ្ធភាព ។